ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ថ្ងៃអង្គារ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
## សិក្ខាសាលាពិគ្រោះយោបល់
## ស្តីពីផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់សាធារណជននិងបណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប សហការជាមួយធនាគារពិភពលោក (WB) នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "**ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២**" នៅថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០១៨ ចាប់ពីម៉ោង ៨:០០ព្រឹក នៅសណ្ឋាគារ៉ាហ្វលឡឺរ៉ូយ៉ាល់ (The Raffles Le Royale)។

សិក្ខាសាលានេះនឹងប្រារព្ធពិធីបើកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ឌី ច័ន្ទផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (គ.គ.អ.ស)**។

សិក្ខាសាលានេះមានគោលបំណងដើម្បីពិនិត្យ និងផ្តល់យោបល់លើរចនាសម្ព័ន្ធ និងខ្លឹមសារនៃសេចក្តីព្រាងផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ ទៅលើបញ្ហាសំខាន់ៗដូចជាៈ គោលដៅ និងសេវាដែលត្រូវអនុវត្ត និរន្តរភាព និងការរៀបចំចាត់ចែងផ្នែកហិរញ្ញវត្ថុ ដែលមានការចូលរួមពីសមាជិក គ.គ.អ.ស តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប អភិបាលខេត្តទាំង ១៨ នៃខេត្តគោលដៅ តំណាងក្រសួងពាក់ព័ន្ធ តំណាងសាលាជាតិរដ្ឋបាលមូលដ្ឋាន តំណាងសកលវិទ្យាល័យពាក់ព័ន្ធ តំណាងស្ថានទូត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាប្រមាណ ១០០នាក់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមអញ្ជើញអ្នកសារព័ត៌មានទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។


*សូមទាក់ទងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមុនតាមរយៈ*

*លេខទូរស័ព្ទ 017 699 987 / 077 785 445 Email: roeurn.phearun@ncdd.gov.kh*

*Website: www.ncdd.gov.kh Facebook Page: www.facebook.com/ncdds/*